# វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារ ANZ Royal

## *សន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៧ :*

## *កាលានុវត្តភាព ដើម្បីកំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម*

**ស្វាគមន៍ និងវគ្គទីមួយ** : ប្រទេសកម្ពុជា : ការពិនិត្យពីស្ថានភាពម៉ាក្រូនៅឆ្នាំ២០០៧ និងក្នុងរយៈពេល មធ្យម-សូចនាករសំខាន់ៗនៃកំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម

**ចក្ខុវិស័យរបស់ CDRI សំរាប់ការអភិវឌ្ឍន៍កម្ពុជា**

**អេង នេត្រា** (វ.ប.ស.អ)

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាងខ្ញុំសូមគោរព សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់

ថ្ងៃនេះ នាងខ្ញុំមានកិត្តិយសយ៉ាងខ្លាំងដែលបានមកធ្វើបទបង្ហាញនៅក្នុងសន្និសិទដ៏មានសារៈសំខាន់នេះ ដែលស្តីអំពីការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជានាពេលអនាគត។ សម្តេចហ៊ុន សែន ក៏បានលើកបង្ហាញរួចមកហើយពីជោគជ័យជាច្រើនរបស់កម្ពុជានៅក្នុងទស្សវត្សនេះនៅក្នុងសុនរក្ថាថាគន្លឹះបើកអង្គសន្និសិទ។ ក្នុងនាមជាវិទ្យាស្ថានស្រាវជ្រាវអំពីគោលនយោបាយឯករាជ្យមួយនៅកម្ពុជា វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាCDRI សូមចែករំលែកនូវការយល់ឃើញរបស់វិទ្យាស្ថាន អំពីការអភិវឌ្ឍន៍ និងបញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះ ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវនៃកម្មវិធីស្រាវជ្រាវរបស់CDRI រួមមានស្ថានភាពសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ចនិងកំណែទំរង់ និងជាទីបញ្ចប់បង្ហាញសំណួរគោលនយោបាយសំរាប់ការពិភាក្សាអោយស៊ីជំរៅសំរាប់ធ្វើការរួមគ្នា ជាដៃគូ ដើម្បីអនាគតដ៏ប្រសើររបស់កម្ពុជា។

ជាបឋមនាងខ្ញុំសុំចាប់ផ្តើមបង្ហាញពី **ចក្ខុវិស័យរបស់ CDRI** សំរាប់កម្ពុជា:

- កំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព និងការបែងចែកឱ្យស្មើភាពគ្នានូវ ផលប្រយោជន៍នៃកំណើន
- សំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ កម្ពុជាក្នុងការកាត់ បន្ថយភាពក្រីក្រអោយបានពាក់កណ្តាលឆ្នាំ ២០១៥
- គ្រប់គ្រង ការប្រើប្រាស់ ដីធ្លី ធនធានធម្មជាតិប្រកបដោយ ចិរភាព
- សមាហរណកម្មជាមួយប្រព័ន្ធពាណិជ្ជកម្ម និង អភិបាលកិច្ចនៅថ្នាក់តំបន់ និងអន្តរជាតិ ស្ថាប័នអភិបាលកិច្ចដែលខ្លាំងនិង ប្រកបដោយប្រសិទ្ធិភាព ឆ្លើយតបចំពោះប្រជាជនរបស់ខ្លួន

ដូចដែលវាគ្មិនមុនៗបានធ្វើការពិភាក្សា កម្មវិធីស្រាវជ្រាវរបស់CDRI ក៏បានរកឃើញដែរថាប្រទេសកម្ពុជាបានសំរេចនូវកំណើនសេដ្ឋកិច្ចដែលគួរអោយកត់សំគាល់។ សេវាសង្គមសំខាន់ៗមួយចំនួនក៏មានលក្ខណៈប្រសើរឡើងរួមមាន

សេវាសុខភាព អប់រំ ហេដ្ឋារចនាសម្ព័ន្ធជនបទ និង ធារាសាស្ត្រ។ ការសិក្សាស្រាវជ្រាវរបស់ CDRI មួយចំនួនបាន សង្កេតឃើញថា កំណើននេះពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យកាត់ដេរ និង វិស័យទេសចរណ៍ ប៉ុន្តែកំណើននេះមិនទាន់ បានបង្កើតអោយគ្រប់គ្រាន់នូវ (១) ឱកាសការងារសំរាប់កំណើននៃយុវជន និង យុវនារីដែលចូលមកក្នុងទីផ្សារការងារ (២) ទំនាក់ទំនង និង ផលប៉ះពាល់ទៅដល់កសិករនៅតំបន់ជនបទ និង (៣) គ្រឿងជំរុញទឹកចិត្តដើម្បីធ្វើអោយ ប្រសើរឡើង និងដើម្បីអភិវឌ្ឍន៏វិស័យគន្លឹះផ្សេងៗទៀត ដូចជា កសិកម្ម ហិរញ្ញវត្ថុ និងធនាគារ។

សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់

ទស្សវត្សកន្លងមកនេះប្រទេសកម្ពុជាសំរេចបានប្រហែល ១ភាគរយ លើការកាត់បន្ថយភាពក្រីក្រប្រចាំឆ្នាំ។ តែទោះជាយ៉ាងណាក្តី ការសិក្សាស្រាវជ្រាវរបស់ CDRI បានបង្ហាញថា កំណើននេះមិនបានបែងចែកប្រកបដោយ សមធម៌ទេ ហើយគំលាតនៃអ្នកមាន និងអ្នកក្រ រវាងអ្នកនៅទីប្រជុំជន និងអ្នកនៅជនបទ មានការរីកធំឡើង។ តួនាទី និង វិភាគទានរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច មានការរីកធំឡើងជាលំដាប់ ជាលទ្ធផលនៃការផ្លាស់ប្តូរមូលដ្ឋានសេដ្ឋកិច្ច ស្ត្រីក្រីក្របំផុតបានលក់កំលាំងពលកម្ម ធ្វើចំណាកស្រុកដើម្បីរកការងារ និង ធ្វើការងារដែលជាតួនាទីរបស់បុរស បន្ថែមលើតួនាទីនៅក្នុងផ្ទះ។ ការសិក្សាស្រាវជ្រាវរបស់ CDRI បង្ហាញអោយឃើញយ៉ាងច្បាស់ដែរថា ប្រជាជនក្រីក្រ និង ប្រជាជនក្រីក្រខ្លាំងជាច្រើន ពឹងផ្អែករឹតតែខ្លាំងឡើងៗ ទៅលើធនធានធម្មជាតិ។ លោក ចន្ទ័ សុផល នឹងធ្វើការ បង្ហាញបន្ថែមលើចំនុចនេះ នៅក្នុងវគ្គបន្ទាប់។

ប្រទេសកម្ពុជាសំបូរទៅដោយធនធានធម្មជាតិដ៏សំបូរបែបដែលបំរើដល់ប្រជាជនរបស់ខ្លួន។ ការគ្រប់គ្រងធនធាន ធម្មជាតិជាកត្តាចាំបាច់ដើម្បីកាត់បន្ថយភាពក្រីក្រ ព្រោះថាធនធានទាំងនោះ គឺជាទ្រព្យសម្បត្តិសំខាន់បំផុតសំរាប់ ប្រជាជនក្រីក្រ។ ការធានាអោយមានការកាន់កាប់ដីធ្លី គឺជាបញ្ហាសំខាន់ណាស់របស់ប្រជាជនក្រីក្រនៅកម្ពុជា។ ប្រជាជនក្រីក្រកាន់តែច្រើនឡើងកំពុងតែបាត់បង់ដីធ្លី ដោយសារការលក់ដោយមានអាសន្ន, បញ្ហាសុខភាពនៅក្នុង គ្រួសារ និងការទន្ទ្រានយកដី។ CDRI គាំទ្រយ៉ាងខ្លាំងចំពោះការផ្តល់លិខិតកាន់កាប់ដី ក៏ប៉ុន្តែការផ្តល់នេះ គួរធ្វើអោយបានលឿន និង ផ្តោតទៅតំបន់ដែលអាចមានផលជាវិជ្ជមានខ្លាំងចំពោះ ការកាត់បន្ថយភាពក្រីក្រ។

ការសិក្សារបស់ CDRI ក៏បានបង្ហាញដែរថា អ្នកក្រីក្រ និងទីទាល់ទាំងនោះពឹងផ្អែកកាន់តែច្រើនឡើងៗ លើផលិតផល ព្រៃឈើ និងជលផលសំរាប់ការចិញ្ចឹមជីវិត។ ការសិក្សាអំពី ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម បានផ្តល់យោបល់ថា សហគមន៍នេសាទអាចផ្តល់ផលប្រយោជន៏ចំពោះសហគមន៏មូលដ្ឋាន ប៉ុន្តែផលប្រយោជន៏ទាំងនោះ មិនបានចែករំលែកឱ្យស្មើភាពគ្នាទេ។ តំបន់នេសាទដែលបានចែកឡូដាក់អោយសហគមន៏ប្រើប្រាស់ ភាគច្រើនផ្តល់ផល ប្រយោជន៏អោយទៅគ្រួសារដែលធូរធារ និង អ្នកខាងក្រៅសហគមន៏។ ការសិក្សាស្រាវជ្រាវលើព្រៃឈើ បានបង្ហាញថា

ការធ្វើសេចក្ដីសំរេចចិត្តតែនៅថ្នាក់កណ្ដាលលើការគ្រប់គ្រងធនធានព្រៃធម្មជាតិ ដោយគ្មានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន នឹងផ្ដល់ផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច និងយ៉ាងធ្ងន់ធ្ងរទៅដល់សហគមន៍។ ជំរើសថ្មីនៃការគ្រប់គ្រងព្រៃឈើតាមបែបសហគមន៏គឺមានសារៈសំខាន់ណាស់ដើម្បីផ្ដល់ជូនប្រជាជននូវលទ្ធភាពប្រើប្រាស់ប្រកប ដោយសមភាពនៅលើផ្ទៃដីព្រៃឈើបន្ទាប់ពីព្រៃឈើទាំងនោះ ត្រូវបានបញ្ឈប់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនសម្បទាន។ បញ្ហាប្រឈមរបស់ការគ្រប់គ្រងធនធាន ធម្មជាតិ កើតដោយសារ (១) កាតព្វកិច្ចមិនច្បាស់លាស់ និង ការកំណត់សិទ្ធអំណាចមិនបានល្អ និង (២) អំពើពុករលួយនៅថ្នាក់មូលដ្ឋានបានធ្វើអោយប៉ះពាល់ដល់ការពង្រឹងច្បាប់ និង បទបញ្ជាក្នុងការគ្រប់គ្រងលើការ ប្រើប្រាស់ និងត្រួតពិនិត្យលើទ្រព្យធនធានធម្មជាតិ។

សម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់

អស់រយៈពេលជាងប៉ុន្មានទសវត្សមកនេះ ប្រទេសកម្ពុជាបានសំរេចនូវសន្តិភាព និងស្ថិរភាពគួរអោយកត់សំគាល់។ កម្ពុជាបានរៀបចំ និងចាត់ចែងការបោះឆ្នោត ហើយបានរៀបចំស្ថាប័នជាតិផ្សេងៗ។ សេវាកម្មសង្គមបាន អភិវឌ្ឍន៏ និងមានការរីកចំរើន។ ការធ្វើវិមជ្ឈការអំណាចបានចាប់ផ្ដើមជាមួយនឹងការបោះឆ្នោតឃុំ/សង្កាត់។ សមត្ថភាពចំណេះដឹងបច្ចេកទេសរបស់មន្ត្រីរដ្ឋាភិបាលកំពុងមានភាពប្រសើរឡើង ក៏ប៉ុន្តែសមត្ថភាពបំពេញការងារ របស់ភ្នាក់ងាររដ្ឋាភិបាលទូទៅនៅមានកំរិត ការពឹងផ្អែកទៅលើការណែនាំនិងបញ្ជាថ្នាក់លើនៅខ្លាំង យន្តការគណនេយ្យភាពផ្លូវការនៅមានលក្ខណៈទន់ខ្សោយ ហើយការសំរបសំរួលខ្សែបណ្ដោយ និងខ្សែទទឹង រវាងក្រសួងផ្សេងៗមានតិចតួចនៅឡើយ។ ការសិក្សារបស់ CDRI បានបង្ហាញអោយឃើញថា អភិបាលកិច្ចថ្នាក់ខេត្តនៅមាន លក្ខណៈមជ្ឈការ និង ទទួលឥទ្ធិពលនយោបាយខ្លាំង បន្ថែមលើបញ្ហាពុករលួយផ្សេងៗ។ ប្រការនេះធ្វើ អោយមានផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច ក៏ដូចជាប្រជាជន ជាពិសេសអ្នកក្រីក្រ និងអាជីវកម្មធនតូច។ ក្រុមប្រឹក្សាឃុំ/សង្កាត់មានសមត្ថភាពអនុវត្តគំរោង និងកសាងហេដ្ឋារចនាសម្ព័ន្ធតូចៗ អាចដោះស្រាយជំលោះថ្នាក់មូលដ្ឋាន ខនៈដែលក្រុមប្រឹក្សានៅមិនទាន់មានសមត្ថភាពការពារថែរក្សានយោបាយបែបប្រជាធិបតេយ្យ ផ្ដល់សេវាកម្មប្រកបដោយប្រសិទ្ធភាព និងមិនអាចគ្រប់គ្រងថែរក្សាធនធានធម្មជាតិសំខាន់ៗបានទេ។ ស្ថាប័នរដ្ឋផ្សេងៗទៀតក៏មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីជំរុញអោយស្ត្រីបានចូលរួមក្នុងការធ្វើការសំរេចចិត្ត ហើយការឆ្លើយតបទៅនឹងតំរូវការរបស់ជនងាយរងគ្រោះដូចជាជនក្រីក្រ ហើយនិងស្ត្រីនៅមិនទាន់គ្រប់គ្រាន់នៅឡើយដែរ។ ជាងនេះទៅទៀត កំណែទំរង់សំខាន់ៗមួយចំនួនរបស់រដ្ឋាភិបាលដូចជា កំនែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ កំនែទំរង់ហិរញ្ញវត្ថុសាធារណៈ កំនែទំរង់រដ្ឋបាល ជាដើមមានដំណើរការយឺតយ៉ាវ ឬ នៅនឹងថ្កល់។

មុននឹងបញ្ចប់ ខ្ញុំសូមបង្ហាញនូវលទ្ធផលសំខាន់ៗបួនរបស់ការសិក្សាយើង ហើយនិងសំនួរគោលនយោបាយ សំខាន់ៗ:

- កំណើនសេដ្ឋកិច្ចមានភាពខ្លាំងក្លា ក៏ប៉ុន្តែយើងត្រូវមានយុទ្ធសាស្ត្ររយៈពេលមធ្យម និង រយៈពេលវែង ជាពិសេសដើម្បីបង្កើនប្រភពកំនើន និងអភិវឌ្ឍវិស័យកសិកម្ម។ តើយើងអាចចែករំលែកលទ្ធផលនៃកំនើនសេដ្ឋកិច្ចប្រទេសដោយរបៀបណា? តើធ្វើយ៉ាងណាដើម្បីអោយវិស័យឯកជន អាចមានតួនាទីក្នុងការវិភាគទានទៅលើកំណើនសេដ្ឋកិច្ច?

- ការកាត់បន្ថយភាពក្រីក្របានសំរេចសមិទ្ធិផលខ្លះ ប៉ុន្តែនៅមានភាពមិនស្មើគ្នា ហើយរូបភាពនៃភាពក្រីក្រផ្សេងៗទៀតកំពុងតែលេចឡើង។ តើយើងត្រូវប្រើវិធីសាស្ត្របែបណា ដើម្បីប្រែក្លាយកំណើនសេដ្ឋកិច្ចអោយទៅជាការកាត់បន្ថយភាពក្រីក្រ? ហើយតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីអោយជនក្រីក្រ និងស្ត្រី ចូលរួមក្នុងការបង្កើតគោលនយោបាយ?

- ធនធានធម្មជាតិកំពុងតែមានភាពរិចរឹល ហើយត្រូវបានគំរាមកំហែងពីប្រព័ន្ធច្បាប់ដែលនៅមានភាពទន់ខ្សោយ និងការខ្វះសមត្ថភាពរបស់ភ្នាក់ងារមូលដ្ឋាន។ តើយើងត្រូវចាត់ចែង និងការពារធនធានធម្មជាតិបែបណា ដើម្បីអោយជនក្រីក្រអាចមានលទ្ធភាពប្រើប្រាស់បាន?

- អភិបាលកិច្ច និងកំណែទំរង់ស្ថាប័ន មិនទាន់ដំណើរការទៅមុខបានល្អគ្រប់គ្រាន់ដើម្បីជួយជំរុញអោយកំណើន និងការអភិវឌ្ឍន៍បានលឿន។ តើយើងត្រូវអនុវត្តកំណែទម្រង់យ៉ាងណាដើម្បីសំរេចគោលដៅអភិវឌ្ឍន៍របស់រដ្ឋាភិបាលកម្ពុជា? តើប្រជាជនខ្មែរយល់យ៉ាងណា ចំពោះតួនាទីរបស់ខ្លួនដែលជាប្រជាជន? តើយើងត្រូវធ្វើយ៉ាងណា ដើម្បីកសាងស្មារតីមោទនភាពសង្គម និងការទទួលខុសត្រូវរបស់ប្រជាជន ក្នុងគោលបំណងបង្កើន និង រក្សាអោយបាននូវការចូលរួមពីសំណាក់សង្គមស៊ីវិល?

យើងខ្ញុំនៅ CDRI ជឿជាក់ថាការសំរេច **ចក្ខុវិស័យ** CDRI **សំរាប់កម្ពុជា** ទាមទារអោយមានការសហការគ្នា និងធ្វើការរួមគ្នា រវាងរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍ទាំងអស់។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្លាំង ចំពោះការយកចិត្តទុកដាក់ស្តាប់របស់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់។